**ទំនាក់ទំនង និង ការទទួលដំណឹង**

ក្រសួងអប់រំ ឡុងប៊ីច ក្នុងរយៈពេលថ្មីៗនេះ បានប្រឹងប្រែងប្រើទំនាក់ទំនងបន្ថែមខ្លះទៀត ដើម្បីជួយមាតាបិតា និង អ្នកគ្រប់គ្រងនៃសិស្សអោយនៅតែមានការទាក់ទងទៅមកជាមួយសាលារៀន និង ទទួលដំណឹងអំពីចម្លើយដោះស្រាយជាបន្តបន្ទាប់ទៅកាន់ការរាលដាលនៃជម្ងឺ កូវីដ-១៩ ។

ដូចបានប្រកាសរួចមកហើយ គឺថា ក្រសួងអប់រំ LBUSD នឹងផ្តល់កម្មវិធីបង្ហាត់មេរៀនភាគច្រើនតាមរយៈ អនឡាញ រហូតដល់ ថ្ងៃទី28 ខែមករា ។ ប៉ុន្តែ សាលារៀនចាប់ផ្តើមធ្វើទាំងប្រយ័ត្ន ដោយបញ្ជូនបន្តិចម្តងៗសម្រាប់សិស្សខ្លះត្រឡប់ចូលសាលារៀនវិញ (សូមបើកមើលបន្ថែមអំពីការរាយផ្សាយដំណឹងក្នុងក្រសួងអប់រំ LBUSD នៅ **ថ្ងៃទី23 ខែតុលា**) ។ លទ្ធផលទាក់ទងផ្នែកសុខភាព និង ក្បួនណែនាំមកពីក្រសួងសុខាភិបាលនឹងជួយសម្រេចប្រើល្បឿន ដែលក្រសួងអប់រំ LBUSD អាចបញ្ជូនសិស្សអោយត្រឡប់ចូលសាលារៀនវិញបានសម្រាប់រៀននៅក្នុងថ្នាក់ផ្ទាល់ ។ **ការតាំងបង្ហាញលទ្ធផលនៃជម្ងឺ កូវីដ-១៩** (Covid-19 Dashboard) គឺឥឡូវនេះ មាននៅតាម lbschools.net សម្រាប់បញ្ជាក់អំពីលទ្ធផលនៃជម្ងឺ កូវីដ ដែលក្រសួងអប់រំ ឡុងប៊ីច កំពុងតែដោះស្រាយអំពី ។ មកដល់ពេលឥឡូវនេះ គឺមានចំនួនសិស្សប្រហែល 1,600 ប៉ុណ្ណោះ ក្នុងចំណោម 70,000 នាក់ ដែលកំពុងរៀននៅតាមសាលាក្នុងក្រសួងអប់រំ ឡុងប៊ីច ជាកម្រិតថ្នាក់ ព្រីស្គូល និង ជាប់ឈ្មោះក្នុងកម្មវិធីទទួលធ្វើ ។ ចំនួនសិស្សជាកំណត់ ដែលទទួលការបង្ហាត់នៅក្នុងថ្នាក់ផ្ទាល់ គឺត្រូវបានយកចិត្តទុកដាក់ទៅកាន់ ដោយធ្វើយ៉ាងប្រយ័ត្នស្របទម្រង់ការផ្នែកសុវត្ថិភាព រួមទាំងបុគ្គលិកផងដែរ ដែលបំពេញមុខងារទៅកាន់សិស្សទាំងអស់នោះ ។

ការប្រឹងប្រែងប្រើទំនាក់ទំនងផ្សេងៗទៀតនៅក្នុងសប្តាហ៍នេះ គឺរាប់បញ្ចូលជា ប៉ូស្តកាដ - postcard ដែលមាតាបិតានឹងបានទទួលពីក្រសួងអប់រំ ឡុងប៊ីច នៅថ្ងៃជាបន្តបន្ទាប់ទៅ ដើម្បីរំលឹកអំពីការរាយពត៌មានថ្មីៗដាក់បញ្ចូលទៅក្នុងប្រព័ន្ធ ParentVue ដើម្បីអោយសាលារៀន និង ការិយាល័យថ្នាក់លើនៃក្រសួងអប់រំ LBUSD អាចបន្តការទាក់ទងបាន និង ផ្តល់ជាដំណឹងថ្មីៗទៅកាន់ក្រុមគ្រួសារ ។ សូមបើកមើលគំរូ ប៉ូស្តកាដ នៅក្នុង វិដេអូ ដែលមានភ្ជាប់ការផ្សាយដំណឹងនេះ ។ ប៉ូស្តកាដ មានរាប់បញ្ចូលទាំងរបៀបបើកប្រើ ParentVue ឬ ការទទួលជំនួយផ្សេងៗសម្រាប់ ParentVue accounts ។ សូមចងចាំថា សាលារៀននៅតែបំពេញកិច្ចការជាច្រើនចំណែក ហើយមានបុគ្គលិកនៅទីនេះសម្រាប់ជួយសិស្ស និង ក្រុមគ្រួសារក្នុងគ្រាដ៏សែនលំបាកនេះ ។